**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ:** ៧៧១ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការកាត់ផ្ទៃដី សរុបទំហំ ៦.២៦១,៩៥ ហិកតា ដែលក្នុងនោះ (១) ទំហំ ៥.៨១៨,៨១ ហិកតា កាត់ចេញពីដីសម្បទានសេដ្ឋកិច្ចក្រុមហ៊ុនភាពីម៉ិច (២) ទំហំ ៤១០,២៨ ហិកតា កាត់ចេញពីដីសម្បទានសេដ្ឋកិច្ចក្រុមហ៊ុនគេនាវិសាល និង (៣) ទំហំ ៣២,៨៦ ហិកតា កាត់ចេញពីដែនគម្របព្រៃឈើឆ្នាំ ២០០២ ដើម្បីធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋនូវដី ទំហំ ៤.៦៧០,៤៩ ហិកតា សំរាប់ធ្វើប្រទានកម្ម ផ្តល់សិទ្ធិជាកម្មសិទ្ធិឯកជន ជូនប្រជាពលរដ្ឋ ចំនួន ១.៣៦៤ គ្រួសារ និងទំហំ ១.៥៩១,៤៦ ហិកតា ទុកជាដីសាធារណៈរបស់រដ្ឋ ស្ថិតនៅក្នុងភូមិសាស្ត្រ ស្រុកក្រគរ ខេត្តពោធិ៍សាត់

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២នសចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១ ដែលប្រកាសឲ្យប្រើច្បាប់ភូមិបាល

២៣-១០-២០១២ -អនុក្រឹត្យលេខ ២០៧៩ អនក្រ.តត ស្តីពី ការតែងតាំងមន្ត្រីរាជការ ៩៥១៤
២៣-១០-២០១២ -អនុក្រឹត្យលេខ ២០៨០ អនក្រ.តត ស្តីពី ការតែងតាំងមន្ត្រីរាជការ ៩៥១៥
២៤-១០-២០១២ -អនុក្រឹត្យលេខ ២០៨១ អនក្រ.តត ស្តីពី ការជូនមេដាយមុនីសារាភ័ណ្ឌ ៩៥១៦
២៤-១០-២០១២ -អនុក្រឹត្យលេខ ២០៨២ អនក្រ.តត ស្តីពី ការជូនមេដាយមុនីសារាភ័ណ្ឌ ៩៥១៩
២៤-១០-២០១២ -អនុក្រឹត្យលេខ ២០៨៣ អនក្រ.តត ស្តីពី ការតែងតាំងមុខតំណែងនាយនគរបាលជាតិ ៩៥២២
២៤-១០-២០១២ -អនុក្រឹត្យលេខ ២០៨៤ អនក្រ.តត ស្តីពី ការតែងតាំងមន្ត្រីរាជការ ៩៥២៣
២៤-១០-២០១២ -អនុក្រឹត្យលេខ ២០៨៥ អនក្រ.តត ស្តីពី ការជូនមេដាយមុនីសារាភ័ណ្ឌ និង មេដាយការងារ ៩៥២៤
២៥-១០-២០១២ -អនុក្រឹត្យលេខ ២០៨៦ អនក្រ.តត ស្តីពី ការដាក់មន្ត្រីរាជការឱ្យចូលនិវត្តន៍ ៩៥២៧
២៥-១០-២០១២ -អនុក្រឹត្យលេខ ២០៨៧ អនក្រ.តត ស្តីពី ការតែងតាំងមន្ត្រីរាជការ ៩៥២៨
២៥-១០-២០១២ -អនុក្រឹត្យលេខ ២០៨៨ អនក្រ.តត ស្តីពី ការតែងតាំងមន្ត្រីរាជការ ៩៥២៩
២៥-១០-២០១២ -អនុក្រឹត្យលេខ ២០៨៩ អនក្រ.តត ស្តីពី ការជូនមេដាយមុនីសារាភ័ណ្ឌ ៩៥៣០
២៥-១០-២០១២ -អនុក្រឹត្យលេខ ២០៩០ អនក្រ.តត ស្តីពី ការជូនមេដាយការងារ ៩៥៣១
២៥-១០-២០១២ -អនុក្រឹត្យលេខ ២០៩១ អនក្រ.តត ស្តីពី ការជូនមេដាយការងារ ៩៥៣៤
២៥-១០-២០១២ -អនុក្រឹត្យលេខ ២០៩២ អនក្រ.តត ស្តីពី ការជូនមេដាយការងារ ៩៥៣៥
២៥-១០-២០១២ -អនុក្រឹត្យលេខ ២០៩៣ អនក្រ.តត ស្តីពី ការជូនមេដាយការងារ ៩៥៣៦
២៥-១០-២០១២ -អនុក្រឹត្យលេខ ២០៩៤ អនក្រ.តត ស្តីពី ការជូនមេដាយស្ត្រីវឌ្ឍនា ៩៥៣៧
២៥-១០-២០១២ -អនុក្រឹត្យលេខ ២០៩៥ អនក្រ.តត ស្តីពី ការជូនមេដាយមុនីសារាភ័ណ្ឌ ៩៥៣៨
២៥-១០-២០១២ -អនុក្រឹត្យលេខ ២០៩៦ អនក្រ.តត ស្តីពី ការជូនមេដាយស្ថាបនាជាតិ ៩៥៤០
២៥-១០-២០១២ -អនុក្រឹត្យលេខ ២០៩៧ អនក្រ.តត ស្តីពី ការជូនមេដាយការងារ ៩៥៤២

## II. ការងារបណ្តាក្រសួង

### ១. ទីស្តីការក្រសួងមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល

០៨-១១-២០១២ -ប្រកាសលេខ ១១២១ ឧរថ.កឧ.ប្រក ស្តីពី ការអនុញ្ញាតឱ្យក្រុមហ៊ុន វ៉ាន់ស្ទូ អ៊ិនធើណែសិនណល បង្កើតរោងចក្រ ផលិតស្បែកជើង, គ្រឿងបន្សំស្បែកជើង ៩៥៤៦
០៨-១១-២០១២ -ប្រកាសលេខ ១១២២ ឧរថ.កឧ.ប្រក ស្តីពី ការអនុញ្ញាតឱ្យក្រុមហ៊ុន ហ៊្វូម៉ា ខសធ្យូម (ខេមបូឌា) ខូ លីមីធីត បង្កើតរោងចក្រ ផលិតសម្លៀកបំពាក់ ៩៥៥០
០៨-១១-២០១២ -ប្រកាសលេខ ១១២៣ ឧរថ.កឧ.ប្រក ស្តីពី ការអនុញ្ញាតឱ្យក្រុមហ៊ុន សុងជី អ៊ិនដាសស្ទ្រៀល (ខេមបូឌា) បង្កើតរោងចក្រ ផលិតគ្រឿងបង្គុំខ្សែអេឡិកត្រូនិក (Wire Harness) ៩៥៥៤

- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០២/០១៦ ចុះថ្ងៃទី៣១ ខែសីហា ឆ្នាំ២០០២ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីព្រៃឈើ
- បានឃើញព្រះរាជក្រឹត្យលេខនស/រកត/០៨០៦/៣៣៩ ចុះថ្ងៃទី០៣ ខែសីហា ឆ្នាំ២០០៦ ស្តីពីគោលការណ៍ និងបញ្ញត្តិអន្តរកាលនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋនិងរបស់នីតិបុគ្គលសាធារណៈ
- បានឃើញអនុក្រឹត្យលេខ៦២ អនក្រ.បក ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញអនុក្រឹត្យលេខ១៧ អនក្រ.បក ចុះថ្ងៃទី០៧ ខែមេសា ឆ្នាំ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ៨៨ អនក្រ.បក ចុះថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០០០ ស្តីពីការបង្កើតក្រុមប្រឹក្សាគោលនយោបាយដីធ្លី
- បានឃើញអនុក្រឹត្យលេខ១១៨ អនក្រ.បក ចុះថ្ងៃទី០៧ ខែតុលា ឆ្នាំ២០០៥ ស្តីពីការគ្រប់គ្រងដីរដ្ឋ
- បានឃើញអនុក្រឹត្យលេខ១៤៦ អនក្រ.បកចុះថ្ងៃទី២៧ខែធ្នូ ឆ្នាំ២០០៥ ស្តីពីសម្បទានដីសេដ្ឋកិច្ច
- បានឃើញសារាចរលេខ ០២ សរ ចុះថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០០៧ ស្តីពីការកាន់កាប់ដីរដ្ឋដោយខុសច្បាប់
- បានឃើញលិខិតលេខ ២៨៣៨ ខ.ពស ចុះថ្ងៃទី ២៦ ខែ វិច្ឆិកា ឆ្នាំ ២០១២ របស់គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តពោធិសាត់
- យោងតាមការចាំបាច់របស់រាជរដ្ឋាភិបាល

## សម្រេច

**មាត្រា ១..**

ត្រូវបានកាត់ចេញនូវផ្ទៃដីសរុបទំហំ ៦.២៦១,៩៥ ហិកតា ដែលក្នុងនោះ (១) ទំហំ ៥.៨១៨,៨១ ហិកតា កាត់ចេញពីដីសម្បទានសេដ្ឋកិច្ចក្រុមហ៊ុនភាពីម៉ិច (២) ទំហំ ៤១០,២៨ ហិកតា កាត់ចេញពីដីសម្បទានសេដ្ឋកិច្ច ក្រុមហ៊ុនរតនាវិសាល និង (៣) ទំហំ ៣២,៨៦ ហិកតា កាត់ចេញពីដែនគម្របព្រៃឈើឆ្នាំ២០០២ ដើម្បីធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋនូវដីទំហំ ៤.៦៧០,៤៩ ហិកតា សំរាប់ធ្វើប្រទានកម្មផ្តល់សិទ្ធិជាកម្មសិទ្ធិឯកជនជូនប្រជាពលរដ្ឋចំនួន ១.៣៦៨ គ្រួសារ និងទំហំ ១.៥៩១,៤៦ ហិកតា ទុកជាដីសាធារណៈរបស់រដ្ឋ ស្ថិតនៅក្នុងភូមិ ដូចខាងក្រោម ៖

១- ភូមិត្រពាំងរំដេញ ឃុំក្បាលត្រាច ស្រុកក្រគរ

ផ្ទៃដីសរុបទំហំ ៨៥៥,៧១ ហិកតា កាត់ចេញពីដីសម្បទានសេដ្ឋកិច្ច ក្រុមហ៊ុនភាពីម៉ិច ដើម្បីធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ ទំហំ ៥៥៨,៦៨ ហិកតា សំរាប់ធ្វើប្រទានកម្មជូនប្រជាពលរដ្ឋចំនួន ១៩៨ គ្រួសារ ដីព្រៃបំរុងទុករបស់រដ្ឋ មានទំហំ ០,៥៣ ហិកតា ដីព្រៃសហគមន៍ ២៨៧,២៧ ហិកតា និងដីសាធារណៈរបស់រដ្ឋដទៃទៀត (ផ្លូវ និងទ្រនាប់ផ្លូវទឹក) ទំហំ ៩,២៣ ហិកតា តាមប្រព័ន្ធកូអរដោណេ Project UTM Zone 48N Datum wgs 1984 និងមាននិយាមកាដូចកំណត់ក្នុងផែនទីឧបសម្ព័ន្ធ នៃអនុក្រឹត្យនេះ។

២- ភូមិក្រឡាញ់ ឃុំក្បាលត្រាច ស្រុកក្រគរ

ផ្ទៃដីសរុបទំហំ ៥.៨០៦,២៨ ហិកតា ក្នុងនោះ ៖

- កាត់ចេញពីដីសម្បទានសេដ្ឋកិច្ចក្រុមហ៊ុនភាពីម៉ិច ៤.៩៦៣,១០ ហិកតា ធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ ទំហំ ៣.៧៣១,១១ ហិកតា សម្រាប់ធ្វើប្រទានកម្មជូនប្រជាពលរដ្ឋចំនួន ១.០៧៣ គ្រួសារ ដីព្រៃបំរុងទុករបស់រដ្ឋ មានទំហំ ៦២,១១ ហិកតា ដីព្រៃសហគមន៍ ២៥៨,១៣ ហិកតា ដីភ្នំ ៣២២,៣៦ ហិកតា និងដីសាធារណៈរបស់រដ្ឋដទៃទៀត (ផ្លូវ និងទ្រនាប់ផ្លូវទឹក) ទំហំ ៥៨៩,៣៩ ហិកតា ។
- កាត់ចេញពីដីសម្បទានសេដ្ឋកិច្ចក្រុមហ៊ុន រតនា វិសាល ៨១០,២៨ ហិកតា ធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ ទំហំ ៣៥១,៨១ ហិកតា សំរាប់ធ្វើប្រទានកម្មជូនប្រជាពលរដ្ឋ ចំនួន ៨៧ គ្រួសារ និងដីសាធារណៈរបស់រដ្ឋដទៃទៀត (ផ្លូវ និងទ្រនាប់ផ្លូវទឹក) ទំហំ ៥៨,៤៧ ហិកតា
- កាត់ចេញពីដែនគម្របព្រៃឈើឆ្នាំ២០០២ ទំហំ ៣២,៨៦ ហិកតា ដើម្បីធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ ទំហំ ២៨,៨៨ ហិកតា សំរាប់ធ្វើប្រទានកម្មជូនប្រជាពលរដ្ឋ ចំនួន ០៦ គ្រួសារ និងដីសាធារណៈរបស់រដ្ឋដទៃទៀត (ផ្លូវ និងទ្រនាប់ផ្លូវទឹក) ទំហំ ៣,៩៨ ហិកតា តាមប្រព័ន្ធកូអរដោណេ Project UTM Zone 48N Datum wgs 1984 និងមាននិយាមកាដូចកំណត់ក្នុងផែនទីឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ។

**មាត្រា ២.-**

ត្រូវបានប្រគល់អាណត្តិកាន់កាប់ និងបែងចែកដីរបស់រដ្ឋដូចមានចែងក្នុងមាត្រា ១ ជូនគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តពោធិ៍សាត់ ធ្វើការគ្រប់គ្រង និងប្រទានកម្មផ្តល់សិទ្ធិជាកម្មសិទ្ធិឯកជនជូនប្រជាពលរដ្ឋដែលបានកាន់កាប់ ប្រើប្រាស់ និងដាំដុះជាក់ស្តែង ចំនួន ១.៣៦៤ គ្រួសារ លើក្បាលដី ចំនួន ២.១០៧ ក្បាលដី និងកម្មសិទ្ធិជាដីរដ្ឋចំនួន ០៦ ក្បាលដី ដែលស្ថិតនៅក្នុងភូមិដូចខាងក្រោម៖

១- ភូមិត្រពាំងវែញ សរុប ៣៣៦ ក្បាលដី

- ផ្តល់សិទ្ធិជាកម្មសិទ្ធិឯកជនជូនប្រជាពលរដ្ឋចំនួន ១៩៨ គ្រួសារ លើក្បាលដីចំនួន ៣៣៤ ក្បាលដី
- កម្មសិទ្ធិជាដីសាធារណៈរបស់រដ្ឋ ០២ ក្បាលដី (ដីបំរុងទុករបស់រដ្ឋ ០១ ក្បាលដី និងដីព្រៃសហគមន៍ ០១ ក្បាលដី)

២- ភូមិក្រឡាញ់ សរុប ១.៧៧៧ ក្បាលដី

- ផ្តល់សិទ្ធិជាកម្មសិទ្ធិឯកជនជូនប្រជាពលរដ្ឋចំនួន ១.១៦៦ គ្រួសារ លើក្បាលដីចំនួន ១.៧៧៣ ក្បាលដី
- កម្មសិទ្ធិជាដីសាធារណៈរបស់រដ្ឋ ០៤ ក្បាលដី (ដីបំរុងទុករបស់រដ្ឋ ០៣ ក្បាលដី និងដីព្រៃសហគមន៍ ០១ ក្បាលដី)

**មាត្រា ៣.-**

ក្នុងពេលដំណើរការវាស់វែង និងបែងចែកជាក់ស្តែង គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តពោធិ៍សាត់ ត្រូវកាត់ចេញនូវចំណែកដីមួយចំនួនសមស្រប ដើម្បីរក្សាទុកសម្រាប់បម្រើផលប្រយោជន៍សាធារណៈ ទាំងសម្រាប់ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និងសង្គម នៅក្នុងមូលដ្ឋាន។

**មាត្រា ៤.-**

បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយពីអនុក្រឹត្យនេះត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា ៥.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីក្រសួងបរិស្ថាន រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ និងអភិបាលនៃគណៈអភិបាលខេត្តពោធិ៍សាត់ ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៣ ខែ ធ្នូ ឆ្នាំ២០១២

នាយករដ្ឋមន្ត្រី

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

កន្លែងទទួល៖

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការ រាជរដ្ឋាភិបាល
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- អគ្គលេខាធិការដ្ឋានអាជ្ញាធរជាតិដោះស្រាយវិវាទដីធ្លី
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៥
- រាជកិច្ច
- ឯកសារកាលប្បវត្តិ

